# អ្វីទៅជាវិធានការសំណង និងវិធានការក្រៅប្រព័ន្ធតុលាការ នៅក្នុងបរិបទតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

**ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១១**

*លឹម ជ័យទ័ត្ត*
*អ្នកសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម*
*មជ្ឈមណ្ឌលឯកសារកម្ពុជា*

## សេចក្តីផ្តើម

ក្រោយពីការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០១ កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ទាក់ទងនឹងជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច កន្លងមក ដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ពាក្យបណ្តឹងឧទ្ធរណ៍របស់ខ្លួនទៅអង្គជំនុំជម្រះតុលាការកំពូលជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការផ្តល់សំណងជូនជនរងគ្រោះ ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលសំណើសុំស្ទើរតែទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយសម្រេចយល់ព្រមផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីនូវសំណើត្រឹមពីរតែប៉ុណ្ណោះ ។ ទី១គឺការបញ្ចូលឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ចូលទៅក្នុងសាលក្រម និងទី២ប្រមូលចងក្រងសេចក្តីថ្លែងសុំអភ័យទោសទាំងអស់ និងការទទួលស្គាល់ការទទួលខុសត្រូវដែល កាំង ហ្គេកអ៊ាវ ហៅ ឌុច ធ្វើឡើងក្នុងអំឡុងពេលសវនាការដាក់បង្ហោះលើគេហទំព័រផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។[1]

វិធាន ២៣ស្ទួនបួន នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញនេះ បានបញ្ជាក់យ៉ាងច្បាស់ថា នៅពេលដែលអង្គជំនុំជម្រះរកឃើញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ អង្គជំនុំជម្រះអាចសម្រេចផ្តល់តែសំណងផ្លូវចិត្ត និងជាសមូហភាពដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ។[2] អង្គជំនុំជម្រះមិនមានសមត្ថកិច្ចផ្តល់សំណងជាប្រាក់ក្នុងលក្ខណៈបុគ្គលទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីដូចជាតុលាការសាមញ្ញនៅ

---

[1] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ប្រកាសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១០ លើសំណុំរឿង ០០១ កាំង ហ្គេកអ៊ាវ ហៅ ឌុច កថាខណ្ឌ ៦៨២ និង៦៨៣ ។

[2] វិធាន ២៣ ស្ទួនបួន នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ធ្វើវិសោធនកម្មថ្ងៃទី០៣ សីហា ២០១១

កម្ពុជាឡើយ ។[៣] ផលវិបាកបែបនេះ គឺដោយសារតែចំនួនដ៏ច្រើននៃដើមបណ្ដឹងរដ្ឋប្បវេណី និងផលវិបាកក្នុងការកំណត់បរិមាណនៃការបាត់បង់ដែលជនរងគ្រោះបានទទួលរង ។[៤]

ដើម្បីដោះស្រាយបញ្ហានេះ កិច្ចប្រជុំពេញអង្គរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសេចក្ដីសម្រេចមួយផ្ដល់អំណាចដល់អង្គភាពគាំពារជនរងគ្រោះ តាមរយៈការធ្វើវិសោធនកម្មវិធានផ្ទៃក្នុងនៅខែកញ្ញា ឆ្នាំ២០១០[៥] ដោយផ្ដល់ផលប្រយោជន៍ដល់ជនរងគ្រោះឲ្យបានកាន់តែទូលំទូលាយជាងមុន ដើម្បីបង្កើត និងអនុវត្តកម្មវិធី និងវិធានការថ្មីៗ ដែលកើតឡើងនៅក្រៅកិច្ចដំណើរការនីតិវិធីតុលាការជាផ្លូវការ ។[៦] វិធានការទាំងឡាយនេះ អាចត្រូវបានបង្កើតឡើងដោយមានកិច្ចសហការជាមួយទីភ្នាក់ងាររបស់រាជរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល នៅក្រៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលផ្ដល់លទ្ធភាពក្នុងការបង្កើតនូវកម្មវិធីទូលំទូលាយជាងមុន ហើយអាចសម្រេចបានក្នុងវង្វង់សមត្ថភាព និងធនធានដែលមាននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ វិធានការទាំងឡាយដែលរៀបរាប់ខាងលើត្រូវបានស្គាល់ថា ជាវិធានការពាក់ព័ន្ធទៅនឹងសំណងនៅក្នុងតុលាការ ។[៧]

## ១) វិធានការពាក់ព័ន្ធនឹងសំណងនៅក្នុងតុលាការ

វិធានការពាក់ព័ន្ធនឹងសំណងនៅក្នុងតុលាការ គឺជាមធ្យោបាយថ្មីមួយដែលបង្កើតឡើងដោយលក្ខណៈឯករាជ្យ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងភាពមិនច្បាស់លាស់នៃការទទួលបានសំណងរដ្ឋប្បវេណីតាមវិធីសាស្ត្រដែលធ្លាប់អនុវត្តនាពេលកន្លងមក ។[៨] វិធានការសំណងនេះ មិនមែនបង្កើតឡើងក្នុងន័យឆ្លើយតបទៅនឹងការទាមទារសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីប្រឆាំងនឹងជនជាប់ចោទឡើយ ក៏ប៉ុន្តែដើម្បីធានាថាសំណងជាក់ស្ដែងដែលផ្ដល់ដោយប្រភពពីខាងក្រៅ ដែលទទួលស្គាល់ព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អាចត្រូវបានអនុវត្តដោយឆាប់រហ័សបន្ទាប់ពីសាលក្រមចូលជាស្ថាពរ ។[៩] វិធាន

---

[៣] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ប្រកាសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១០ លើសំណុំរឿង ០០១ កាំង ហ្កេកអ៊ាវ ហៅ ឌុច ទំព័រ៣៩៦(ភាសាខ្មែរ) កំណត់សំគាល់យោងជើងទំព័រលេខ ១១៨៤ ។

[៤] ដូចខាងលើ ។

[៥] សូមមើលវិធាន២៣ស្ទួនបួន៣នៃវិធានផ្ទៃក្នុងដែលត្រូវបានធ្វើវិសោធនកម្មលើកទី ៦ នៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១០ ដោយកិច្ចប្រជុំពេញអង្គរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

[៦] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ប្រកាសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១០ លើសំណុំរឿង ០០១ កាំង ហ្កេកអ៊ាវ ហៅ ឌុច ទំព័រ៣៩៨(ភាសាខ្មែរ) កំណត់សំគាល់យោងជើងទំព័រលេខ ១១៨៩ ។

[៧] ដូចខាងលើ ។

[៨] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១១ ទាក់ទងនឹងការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងទាមទារ ដោយអនុលោមតាមវិធាន ២៣ ស្ទួនបួន(៣)នៃវិធានផ្ទៃក្នុង ។

[៩] ដូចខាងលើ ។

២៣ ស្ទួនបួន (៣) (ខ) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រគល់ភារកិច្ចក្នុងការបង្កើតគម្រោងនានាពាក់ព័ន្ធនឹងវិធានការសំណងជូនអង្គភាពគាំពារជនរងគ្រោះដើម្បីចាត់ចែង និងអនុវត្តន៍ ដោយសារតែអង្គភាពនេះកំពុងតែធ្វើការមួយចំនួនទាក់ទងទៅនឹងវិធានការក្រៅប្រព័ន្ធតុលាការដែរ ។[១០] ដើម្បីឲ្យសំណងជាក់ស្តែង ដែលផ្តល់ដោយប្រភពពីខាងក្រៅអាចអនុវត្តបានដោយឆាប់រហ័សបន្ទាប់ពីសាលក្រមចូលជាស្ថាពរ អង្គភាពគាំពារជនរងគ្រោះត្រូវរៀបចំសំណង(ជាលក្ខណៈបច្ចេកទេសតាមរយៈការគ្រប់គ្រងគម្រោង) ក្នុងពេលតំណាលគ្នាទៅនឹងដំណើរការសវនាការ ដែលមានមន្ត្រីគ្រប់គ្រងគម្រោងម្នាក់ជាអ្នកទទួលបន្ទុកលើការរៀបចំទម្រង់នៃសំណងទាំងអស់ ដែលបានចង្អុលបង្ហាញដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី[១១] ហើយមន្ត្រីគ្រប់គ្រងគម្រោងនេះនឹងត្រូវធានាលើបញ្ហាថវិកា និងការត្រៀមខ្លួនរួចជាស្រេចក្នុងការអនុវត្តនូវសំណងនេះនៅពេលសាលក្រមចូលជាស្ថាពរ ។[១២] ដើម្បីទទួលបានសំណងដែលស្នើសុំ អង្គជំនុំជម្រះបានតម្រូវឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវមានកិច្ចសហការស្អិតរមួត ជាមួយនឹងមន្ត្រីគ្រប់គ្រងគម្រោងកម្មវិធីសំណងចាប់តាំងពីដំណាក់កាលដំបូងនៃការចាប់ផ្តើមនីតិវិធីក្នុងសំណុំរឿង ដើម្បីធានាថាបណ្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់មានលក្ខណៈប្រាកដប្រជាតាមបច្ចេកទេស មានតួលេខច្បាស់លាស់ និងមានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់អនុវត្ត ។[១៣] ទោះបីជាយ៉ាងណាក៏ដោយ វិធានការសំណងដែលស្នើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចនឹងត្រូវបានបដិសេធចោលដោយអង្គជំនុំជម្រះសាលាដំបូង ប្រសិនបើគម្រោងសំណងដែលបង្កើតឡើងនោះ ត្រូវចំណាយថវិកាច្រើន ចំណាយពេលវេលាច្រើន ឬការបង្ហាញពីកម្មវត្ថុនៃសំណងពុំមានភាពច្បាស់លាស់ ។[១៤] វិធានការនានាដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំតាមរយៈអង្គភាពគាំពារជនរងគ្រោះ ត្រូវបញ្ជាក់ជាមុនអំពីខ្លឹមសារជាក់លាក់ស្តីពីសំណងនៅដំណាក់កាលដំបូង[១៥] ដូចដែលអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានធ្វើនៅក្នុងសវនា

---

[១០] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១១ ទាក់ទងនឹងការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងទាមទារ ដោយអនុលោមតាមវិធាន ២៣ ស្ទួនបួន(៣) នៃវិធានផ្ទៃក្នុង ។

[១១] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ទាក់ទងនឹងការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងទាមទារ ដោយអនុលោមតាមវិធាន២៣ ស្ទួនបួន (៣) នៃវិធានផ្ទៃក្នុង ។

[១២] ដូចខាងលើ ។

[១៣] ដូចខាងលើ ។

[១៤] ដូចខាងលើ ។

[១៥] ដូចខាងលើ ។ សូមមើលវិធាន ៨០ ស្ទួន(៤) នៃវិធានផ្ទៃក្នុង ដែលចែងថា៖ « អង្គជំនុំជម្រះសាលាដំបូង អាចណែនាំសហមេធាវីនាំមុខឲ្យផ្តល់ឯកសារជាក់លាក់ស្តីអំពីសំណង ដែលខ្លួនមានបំណងស្នើសុំនៅក្នុងបណ្តឹងទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្តនិងសមូហ

វការបឋម[16] និងសវនាការស្តីពីការកំណត់ដាក់លាក់នូវសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី[17] ដើម្បីធានាអំពីវិសាលភាព និងប្រសិទ្ធភាពនៃវិធានការដែលបានស្នើសុំ និងដើម្បីទុកឱកាសឲ្យអង្គជំនុំជម្រះសាលាដំបូងមានលទ្ធភាពពិនិត្យមើល និងផ្តល់ការណែនាំថាតើសំណងដែលបានស្នើសុំនោះ ស្របជាមួយក្របខ័ណ្ឌគតិយុត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ ។[18] គម្រោងទាក់ទងនឹងវិធានការសំណងដែលនឹងត្រូវអនុវត្តដោយអង្គភាពគាំពារជនរងគ្រោះ ត្រូវបានចងក្រងជាបួនជំពូកដូចជា គម្រោងរំលឹកការចងចាំ គម្រោងស្តារនីតិសម្បទាឡើងវិញ គម្រោងចងក្រងឯកសារ និងការអប់រំ និងគម្រោងសំណងផ្សេងៗ ។[19]

## ២) វិធានការក្រៅប្រព័ន្ធតុលាការ

ចំណែកឯវិធានការក្រៅប្រព័ន្ធតុលាការ គឺជាវិធានការដែលពុំជាប់ពាក់ព័ន្ធនឹងសំណងនៅក្នុងតុលាការ ។ វិធានការក្រៅប្រព័ន្ធតុលាការមិនមែនជាសំណងនោះទេ ប៉ុន្តែវាជាការឆ្លើយតបរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចំពោះជនរងគ្រោះ និងប្រជាជនកម្ពុជាទូទាំងប្រទេសឲ្យទទួលបាននូវការផ្សះផ្សា និងការព្យាបាលរបួសផ្លូវចិត្ត ។[20] ការឆ្លើយតបនៃវិធានការក្រៅប្រព័ន្ធតុលាការនេះ មានលក្ខណៈជាសមូហភាព និងផ្លូវចិត្ត ដូចគ្នានឹងទម្រង់នៃសំណងដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះដែរ ។ អង្គភាពគាំពារជនរងគ្រោះមានភារកិច្ចជាអ្នកសម្របសម្រួលគម្រោងវិធានការក្រៅប្រព័ន្ធតុលាការ តាមរយៈការសហការជាមួយម្ចាស់ជំនួយ រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធ្វើការឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះ និងប្រជាជនទូទាំងប្រទេស ។ វិធានការក្រៅ

---

ភាព ក្នុងអំឡុងពេលដាក់លាក់ដែលបានកំណត់ ដោយអង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន ២៣ស្ទួនបួន(៣)(ខ) ។ នៅដំណាក់កាលក្រោយមកទៀត អង្គជំនុំជម្រះនឹងត្រូវកំណត់កាលបរិច្ឆេទចុងក្រោយសម្រាប់សហមេធាវីនាំមុខក្នុងការដាក់បណ្តឹងទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្តនិងសមូហភាព ។»

[16] អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការបឋមលើសំណុំរឿងលេខ០០២ ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ ប្រឆាំងនឹងជនជាប់ចោទបួនរូប រួមមាន ជនជាប់ចោទ ខៀវ សំផន នួន ជា អៀង សារី និងអៀង ធីរិទ្ធ ។

[17] អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តីពីការកំណត់ដាក់លាក់នូវសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសវនាការលើសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ពីថ្ងៃទី១៩ ដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ ។

[18] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១១ ទាក់ទងនឹងការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងទាមទារ ដោយអនុលោមតាមវិធាន ២៣ ស្ទួនបួន(៣) នៃវិធានផ្ទៃក្នុង ។

[19] សូមអានអត្ថបទៈ សវនាការស្តីពីការកំណត់ដាក់លាក់នូវសំណង និងសវនាការលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការពីថ្ងៃទី១៩-២០ ខែតុលា ឆ្នាំ២០១១ របស់មជ្ឈមណ្ឌលឯកសារសម្រាប់ ខែតុលា ឆ្នាំ២០១១ ដោយ ឌី សុជាតា និង លីម ជ័យទត្ត ។

[20] ការឆ្លើយតបទៅនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី ពីសំណាក់ លោក គាន់ វិសាល មន្ត្រីគ្រប់គ្រងគម្រោងទាក់ទងនឹងវិធានការក្រៅប្រព័ន្ធតុលាការរបស់អង្គភាពគាំពារជនរងគ្រោះ នៅក្នុងវេទិការថ្នាក់តំបន់នៃដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សំណុំរឿងលេខ ០០២ ដែលបានប្រព្រឹត្តធ្វើនៅខេត្ត កំពង់ចាម កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ។

ប្រព័ន្ធតុលាការអាចអនុវត្តបានគ្រប់ពេលវេលា គ្រប់ទីកន្លែង ដោយមិនចាំបាច់មានសាលក្រមពីតុលាការសម្រេចឲ្យអនុវត្តដូចជាសំណងដែលដើមបណ្តឹងរដ្ឋប្បវេណីបានទាមទារទៅអង្គជំនុំជម្រះឡើយ[២១] ។ ទោះបីជានៅក្នុងករណីជនជាប់ចោទ ត្រូវបានតុលាការរកឃើញថាជាជនក្រីក្រ ឬទទួលមរណភាពក៏ដោយ វិធានការក្រៅប្រព័ន្ធតុលាការនឹងនៅតែអាចបន្តអនុវត្តគម្រោងនានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះ និងប្រជាជនកម្ពុជាទូទាំងប្រទេស ដែលបានទទួលរងការបាត់បង់ និងរបួសផ្លូវចិត្តបានដដែល ។ ការអនុវត្តបែបនេះ គឺដើម្បីផ្តល់ប្រយោជន៍ទៅដល់ជនរងគ្រោះឲ្យកាន់តែទូលំទូលាយ ។

**សន្និដ្ឋាន**

ទោះបីជាវិធានការក្រៅប្រព័ន្ធតុលាការ និងវិធានការសំណងក្នុងតុលាការផ្តល់ប្រយោជន៍ទៅដល់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងណាក៏ដោយ ការអនុវត្តវិធានការទាំងនេះអាចជួបប្រទះបញ្ហាប្រឈមចំបងៗមួយចំនួនដូចជា ការខ្វះខាតធនធាន និងសមត្ថភាពនៅមានកម្រិតរបស់អង្គភាពគាំពារជនរងគ្រោះ ។[២២] ប្រភពថវិកាដែលនឹងត្រូវយកមកអនុវត្តគម្រោងសំណងក្រៅប្រព័ន្ធតុលាការនេះទៀតសោត បានក្លាយទៅជាបន្ទុកថ្មីមួយបន្ថែមលើអង្គភាពគាំពារជនរងគ្រោះ ។ ដូច្នេះអង្គភាពគាំពារជនរងគ្រោះចាំបាច់ត្រូវតែស្វែងរកថវិកា និងការសម្របសម្រួលពីរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូរម្ចាស់ជំនួយនានា ដើម្បីឲ្យការអនុវត្តគម្រោងទាំងនេះអាចឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីឲ្យបានកាន់តែឆាប់រហ័ស ។

[២១] ការឆ្លើយតបទៅនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី ពីសំណាក់ លោក តាន់ វិសាល មន្ត្រីគ្រប់គ្រងគម្រោងទាក់ទងនឹងវិធានការក្រៅប្រព័ន្ធតុលាការរបស់អង្គភាពគាំពារជនរងគ្រោះ នៅក្នុងវេទិការថ្នាក់តំបន់នៃដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សំណុំរឿងលេខ ០០២ ដែលបានប្រព្រឹត្តធ្វើនៅខេត្ត កំពង់ចាម កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ។

[២២] សូមមើល សាលាកបត្រព័ត៌មានរបស់អង្គភាពគាំពារជនរងគ្រោះ “ការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការនីតិវិធីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា” ឆ្នាំទី១ ច្បាប់ទី២ មករា-មិនា ឆ្នាំ ២០១១ ទំព័រ ៩ (ភាសាខ្មែរ) ។